ស-សបាសាក់ SA SA BASSAC
#18 (upstairs) Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia
+855 (0)77 374 110
www.sasabassac.com

## សេចក្តីប្រកាសព័ត៌មាន

សំរាប់ការផ្សាយបន្ទាន់
ថ្ងៃអង្គារ ទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១

# វិចិត្រសាល ស-សបាសាក់ បើកសម្ពោធជាមួយនិងពិព័រណ៌ "រណ្តៅបេ" ដោយ វណ្ឌី រតនា

**ភ្នំពេញ** - វិចិត្រសាល ស-សបាសាក់ មានសេចក្តីរីករាយក្នុងការប្រកាសពិធីសម្ពោធជាផ្លូវការរបស់ខ្លួន ជាមួយនិងពិព័រណ៌សិល្បៈដែលមានចំណងជើងថា "រណ្តៅបេ" ដោយ វណ្ឌី រតនា នៅថ្ងៃទី ១៧ កុម្ភៈ វេលាម៉ោង ៦ ល្ងាច ។ បថកថារបស់សិល្បករនឹងធ្វើឡើងនៅថ្ងៃទី ១៨ កុម្ភៈ វេលាម៉ោង ៦ ល្ងាច ។ ពិព័រណ៌នេះ បើកជូនទស្សនា រហូតដល់ថ្ងៃទី ២០ មីនា ២០១១ ។

**អំពីពិព័រណ៌ "រណ្តៅបេ"**
វណ្ឌី រតនា និយាយថា៖ "មានពាក្យចាស់ខ្មែរមួយឃ្លាតែងនិយាយថា ឮ ១000 ដង មិនស្មើឃើញ ១ ដង ។"

នៅចន្លោះឆ្នាំ ១៩៦៤ ដល់ ១៩៧៥ កងទ័ពសហរដ្ឋអាមេរិកបានធ្វើការទម្លាក់គ្រាប់បែកចំនួន ២,៧៥៦,៩៤១ តោន (២៣០,៥១៦ ដង លើ ១១៣,៧១៦ ទីកន្លែង) មកលើប្រទេសកម្ពុជា ដែលជាប្រទេសមួយប្រកាន់យកគោលនយោបាយអព្យាក្រឹត ។ តួលេខនេះមិនត្រូវបានគេទទួលស្គាល់ទេរហូតមកទល់ឆ្នាំ ២000 គឺនៅពេលដែលលោកអតីតប្រធានាធិបតី ប៊ីល គ្លីនតុន បានមកធ្វើទស្សនកិច្ចនៅប្រទេសវៀតណាម ហើយបានបង្ហើបដោយសៀមស្ងាត់នូវទិន្នន័យរបស់កងទ័ពអាកាស ស្តីអំពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើអតីតតំបន់ឥណ្ឌូចិន ។[1]

ដោយមិនពេញចិត្តចំពោះកង្វះខាតនៃការធ្វើកំណត់ត្រាឯកសារស្តីពីបញ្ហានេះ អ្នកថតរូប វណ្ឌី រតនា បានធ្វើដំណើរទៅកាន់ខែត្រចំនួន ១០ ក្នុងប្រទេសកម្ពុជា ដែលបានទទួលរងការទម្លាក់គ្រាប់បែកធ្ងន់ធ្ងរជាងគេពីយុទ្ធនាការកងទ័ពរបស់សហរដ្ឋអាមេរិកនៅក្នុងអំឡុងពេលសង្គ្រាមវៀតណាម ។ នៅក្នុងការធ្វើដំណើរនេះ រតនា បានបង្កើតទំនាក់ទំនងជាមួយអ្នកភូមិក្នុងការស្វែងរកទីតាំង និងផ្តល់សក្ខីកម្មអំពីវត្តមាននៃរណ្តៅជាច្រើនដែលកកើតឡើងដោយសារការទម្លាក់គ្រាប់បែក ដែលត្រូវបានហៅជាភាសាខ្មែរថា "រណ្តៅបេ" ។

លទ្ធផលនៃស្នាដៃនេះគឺជា កំរងរូបថតទេសភាពដ៏ស្ងៀមស្ងាត់ និងអាប៉ិកំបាំងចំនួន ៩ រូប រួមជាមួយនិងខ្សែភាពយន្តឯកសារមួយដែលក្នុងនោះអ្នកភូមិរៀបរាប់ពីការចងចាំរបស់ពួកគាត់អំពីការទម្លាក់គ្រាប់បែក និងទំនាក់ទំនងបច្ចុប្បន្នរបស់ពួកគេជាមួយនិងរណ្តៅបេទាំងនោះ ។ "រណ្តៅបេ" អនុញ្ញាតអោយទស្សនិកជនស្វែងយល់អំពីភាពផុយស្រួយនិងស្មារតីរស់រានឡើងវិញរបស់ប្រជាជននិងទឹកដី និងអោយទស្សនិកជនពិចារណាសារជាថ្មីនូវប្រវត្តិសាស្ត្រនៃសកម្មភាពរបស់សហរដ្ឋអាមេរិកក្នុងអំឡុងពេលសង្គ្រាមវៀតណាម និងសកម្មភាពនៃអំពើហិង្សានានាស្រដៀងគ្នានេះនៅទូទាំងពិភពលោក ។

---

[1] ដោយ Taylor Owen និង Ben Kiernan, "Bombs Over Cambodia," ទស្សនាវដ្តី Walrus (ប្រទេសកាណាដា), ៩ កញ្ញា ២០០៩

ពិព័រណ៍ “រណ្ដៅបេ” ត្រូវបានដាក់បង្ហាញជាលើកដំបូងនៅឯសារមន្ទីរ Hessel នៃមណ្ឌលសំរាប់ការសិក្សារៀបចំពិព័រណ៍សិល្បៈរបស់មហាវិទ្យាល័យ Bard សហរដ្ឋអាមេរិក ដែលរៀបចំឡើងដោយកញ្ញា ហ្វ្រានសេស្កា សូណារា ។ ពិព័រណ៍នេះត្រូវបានជ្រើសរើសដោយទស្សនាវដ្ដីសិល្បៈអាស៊ីប៉ាស៊ីហ្វិកលេខប្រចាំឆ្នាំ ថាជាពិព័រណ៍មួយក្នុងចំណោមពិព័រណ៍នៅសារមន្ទីរចំនួន ១០ ដែលគួរទស្សនា ។ ពិព័រណ៍នេះ ក៏ជាផ្នែកមួយនៃគំរោង UNFIXED របស់ប្រទេសហូឡង់ ហើយនឹងត្រូវដាក់បង្ហាញជាបន្តទៀតនៅឯវិចិត្រសាល San Art នៅទីក្រុងហូជីមិញ នៅក្នុងខែមេសា ឆ្នាំ ២០១១ ខាងមុខនេះ ។

**អំពីសិល្បករ**

វណ្ណី រតនា កើតនៅក្នុងទីក្រុងភ្នំពេញ ឆ្នាំ ១៩៨០ ដែលជាសម័យដ៏ផុយស្រួយ ខណៈពេលដែលកម្ពុជាទើបតែងើបពីរបបខ្មែរក្រហម ។ រតនា បារម្ភពីកង្វះខាតនៃកំណត់ត្រាឯកសារស្ដីពីរឿងរ៉ាវ ចរិតលក្ខណៈ និងទីកន្លែងប្រវត្តិសាស្ត្រដែលមានលក្ខណៈដោយឡែកចំពោះវប្បធម៌របស់គាត់ ។ កំរងស្នាដៃរូបថតរបស់គាត់ ត្រូវបានថតផ្ចិតដោយប្រើម៉ាស៊ីនថតប្រើហ្វីលជាច្រើនប្រភេទ ហើយរួមបញ្ចូលគ្នារវាងរូបថតបែបសារព័ត៌មាននិងការងារបែបសិល្បៈ ។ លក្ខណៈនៃប្រធានបទស្នាដៃរបស់គាត់ ភាគច្រើនជំរុញទៅលើសពីការធ្វើកំណត់ត្រាឯកសារដ៏ច្រើនលើសលប់ដែលរំខានដល់ការអភិវឌ្ឍរបស់កម្ពុជា ហើយបង្កើតទំនាក់ទំនងដ៏សំខាន់ៗរវាងរឿងរ៉ាវបច្ចុប្បន្ននិងគុណតម្លៃប្រវត្តិសាស្ត្រដែលជក់ជាប់នៅក្នុងកំណត់ត្រាជាហូរហែរក្នុងសម័យសព្វថ្ងៃ ។

***ពិព័រណ៍សំរាំងមួយចំនួនរួមមាន*** ៖ “រណ្ដៅបេ”, សារមន្ទីរ Hessel, ទីក្រុងញូយ៉ក (២០១០); “អគ្គីភ័យប្រចាំឆ្នាំ”, ពិព័រណ៍សិល្បៈសហសម័យអាស៊ីប៉ាស៊ីហ្វិកសំរាប់ ៣ ឆ្នាំម្ដងលើកទី ៦, ទីក្រុងប្រ៊ីសបេន ប្រទេសអូស្ត្រាលី (២០០៩); “ដំណើរឆ្លងកាត់”, វិចិត្រសាលស-ស, ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា (២០០៩); “TADAIMA: ស្វែងរកផ្ទះដ៏គួរអោយស្រលាញ់”, សកលវិទ្យាល័យយូស៊ូ, ប្រទេសជប៉ុន (២០០៩); “Magnetic Power”, មណ្ឌលកូរ៉េ-អាស៊ាន, ប្រទេសកូរ៉េ (២០០៩); “តាំងពីកាលនោះមកទល់បច្ចុប្បន្ន៖ សិល្បៈសហសម័យមកពីប្រទេសកម្ពុជា”, វិចិត្រសាល 10 Chancery Lane, ទីក្រុងហុងកុង (២០០៩); “អាស៊ីមួយផ្សេងទៀត”, ពិព័រណ៍រូបថត Noorderlicht, ប្រទេសហូឡង់ (២០០៦)។

**អំពី ស-សបាសាក់**

ស-សបាសាក់ គឺជាទីកន្លែងសិល្បៈមួយដែលប្ដេជ្ញាក្នុងការបង្កើត សម្របសម្រួល និងចែករំលែកគម្រោងនិងវប្បធម៌ទស្សសិល្បៈសហសម័យនៅក្នុងនិងចេញពីប្រទេសកម្ពុជា ។ កម្មវិធីរបស់យើងផ្ដោតលើបទពិសោធន៍ច្នៃប្រឌិតនិងអប់រំនៃពិព័រណ៍ស្នាដៃសិល្បៈរបស់សិល្បករខ្មែរ ។ ដោយយកចិត្តទុកដាក់នៅក្នុងបរិបទប្រទេសកម្ពុជា យើងប្ដេជ្ញាជួយគាំទ្រដល់ការងារដ៏សម្បូរបែបរបស់សិល្បករ អ្នករៀបចំពិព័រណ៍សិល្បៈ អ្នកនិពន្ធ និងផលិតករនៃស្នាដៃវប្បធម៌នានា ដើម្បីជាយានក្នុងការចែករំលែកចំណេះដឹង និងការបន្តនូវប្រពៃណី ខណៈពេលដែលពង្រីកនូវសក្តានុពលភាពនិងការយល់ដឹងថាតើសិល្បៈអាចជាអ្វីខ្លះ ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង អ្នកស្រី អេរីន ឃ្លីសុន តាមរយៈទូរស័ព្ទ **០១២ ៥០៧៩១៧** ឬអ៊ីម៉េល erin@sasabassac.com ។